ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋាន រតនាគារជាតិ
លេខ : 1501 អ.រតន.

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានីភ្នំពេញ ថ្ងៃទី 10 ខែ 8 ឆ្នាំ ២០១០

# សេចក្តីណែនាំ
## ស្តីពី
## ការកំណត់លិខិតយុត្តិការចំណាយមូលនិធិគាំទ្រការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹង សុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និង កិច្ចការពារកុមារនៅឃុំ សង្កាត់

យោងសេចក្តីណែនាំលេខ ០៥១ សណន.គជអប ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១០ ស្តីពីការអនុវត្តមុខងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារឃុំ សង្កាត់ ។

ដើម្បីមានមូលដ្ឋានក្នុងការរៀបចំលិខិតយុត្តិការចំណាយភ្ជាប់តាមអាណត្តិបើកប្រាក់ អគ្គនាយកដ្ឋានរតនាគារជាតិសូមធ្វើការណែនាំសម្រាប់អនុវត្តដែលមានខ្លឹមសារដូចតទៅ ៖

**១-** មូលនិធិដែលមានទឹកប្រាក់ ៤.១៦៩.០០០ រៀល ( ១.០០០ ដុល្លារអាមេរិក ) ដែលបានពី UNDP ត្រូវបានបញ្ចូលទៅជាចំណូលថវិការបស់ឃុំ សង្កាត់នៅក្នុងត្រីមាសទី ១ ឆ្នាំ ២០១០ រួចហើយ ដោយបានកត់ត្រាទៅក្នុងគណនីលេខ ៧២ ( ប្លង់គណនេយ្យឃុំ សង្កាត់ ) ។ ក្នុងចំនួនទឹកប្រាក់ ៤.១៦៩.០០០ រៀល មានចំនួន ៣.៣៣៥.២០០ រៀលពុំទាន់បានចំណាយ ។

**២-** ការចំណាយថវិកាដើម្បីបម្រើអោយសកម្មភាពលើកកំពស់សុខភាពមាតា សកម្មភាពបង្កើត និង ដំណើរការមត្តេយ្យសិក្សាសហគមន៍ សកម្មភាពលើកកំពស់អនាម័យ និង សកម្មភាពលើកកំពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ ត្រូវប្រើអនុគណនីលេខ ៦២.០៩.០២ ។

**៣-** ការចំណាយលើសកម្មភាពទាំង បួន (ដូចចំណុច ២) អាចធ្វើតាមរូបភាពបេឡាបុរេប្រទាន ឬ តាមរូបភាពទូទាត់ត្រង់ ។

**៤-** ការបើកផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូមត្តេយ្យតាមបេឡាបុរេប្រទាន ឃុំ សង្កាត់ត្រូវភ្ជាប់ជាមួយអាណត្តិទូទាត់នូវ ប័ណ្ណចំណាយប្រាក់បេឡា និង កិច្ចសន្យា ( ផ្តល់តែមួយលើកនៅគ្រាដំបូង ) ។

**៥-** ការបើកផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូមត្តេយ្យមានចំនួនច្រើននាក់ តាមរូបភាពទូទាត់ត្រង់ ឃុំ សង្កាត់ត្រូវភ្ជាប់ជាមួយអាណត្តិបើកប្រាក់នូវ តារាងប្រាក់ឧបត្ថម្ភ (ដូចគំរូភ្ជាប់មកជាមួយ) និង កិច្ចសន្យា ( ផ្តល់តែមួយលើកនៅគ្រាដំបូង ) ។ ពេលបើកប្រាក់ឧបត្ថម្ភ គ្រូមត្តេយ្យត្រូវចុះហត្ថលេខាទទួលប្រាក់នៅលើតារាងប្រាក់ឧបត្ថម្ភ ។ ឃុំសង្កាត់ត្រូវ

៦

ភ្ជាប់តារាងប្រាក់ឧបត្ថម្ភដែលមានហត្ថលេខាអ្នកទទួលប្រាក់លើកមុនជាមួយអាណត្តិបើកប្រាក់ និង តារាងប្រាក់ឧបត្ថម្ភសម្រាប់ខែថ្មី ។

**៦-** ការចំណាយឧបត្ថម្ភលើការធ្វើដំណើររបស់ស្ត្រីមានផ្ទៃពោះ ក្រីក្រទៅមន្ទីរពេទ្យ សោហ៊ុយដឹកជញ្ជូន ឬ ធ្វើដំណើរក្នុងកម្មវត្ថុរំដោះជនរងគ្រោះពីអំពើហឹង្សា ការផ្តល់ប្រាក់សម្រាប់ទិញសំភារៈអនាម័យ សំភារៈកសាងបង្គន់អនាម័យ ( លូ ស័ង្កសី ចានបង្គន់ .......) ចំណាយសង្គ្រោះជនក្រីក្រ អាហារសម្រន់ក្នុងការប្រជុំផ្សព្វផ្សាយ...... ត្រូវភ្ជាប់ជាមួយនូវប័ណ្ណចំណាយប្រាក់ពីបេឡាបុរេប្រទាន និង ពាក្យស្នើសុំប្រាក់ឧត្ថម្ភរបស់សាមីជន ( គំរូលេខ ៤ នៃ សេចក្តីណែនាំលេខ ០៥១ សណន.គជអប ) ។

**៧-** នៅដំណាច់ឆ្នាំ ឃុំ សង្កាត់ត្រូវបញ្ជូនតារាងរបាយការណ៍រីកចម្រើន ស្តីពីការអនុវត្តថវិកាសម្រាប់អភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ ( ទម្រង់លេខ ៩ នៃ សេចក្តីណែនាំលេខ ០៥១ សណន.គជអប ) មករតនាគារពាក់ព័ន្ធ ដើម្បីអោយគណនេយ្យករធ្វើការបន្ថយពីទឹកប្រាក់ចំណូលថវិកាក្នុងឆ្នាំ ( លេខនាកត់ត្រា ឥណពន្ធ គណនី ៧២ និង ឥណទាន គណនី ៤០.៨ ) ។

**៨-** នៅឆ្នាំបន្ទាប់មេឃុំ ចៅសង្កាត់ ត្រូវបញ្ចូលតួលេខដែលបានបន្ថយពីចំណូលនៅឆ្នាំមុនទៅក្នុងគម្រោងថវិកា ។ នៅពេលដែលគម្រោងថវិកាត្រូវបានផ្តល់អនុលោមភាព និងប្រគល់មករតនាគារ គណនេយ្យករឃុំ សង្កាត់ ត្រូវកត់ត្រាជាចំណូលថវិកា ( ឥណពន្ធ គណនី ៤០.៨ និង ឥណទាន គណនី ៧២ ) ។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីប្រធានគ្រប់នាយកដ្ឋាននៃអគ្គនាយកដ្ឋាន និង អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានរតនាគារជាតិ ចាត់ចែងអនុវត្តអោយទទួលបានលទ្ធផលល្អប្រសើរ ។

ជ.រដ្ឋមន្ត្រី ទទួលបន្ទុកជា
អគ្គនាយក អគ្គនាយកដ្ឋានរតនាគារជាតិ

**ខិន យន**

ចំលងជូន :

- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- លេខាធិការដ្ឋាននៃគណៈកម្មាធិការគាំទ្រការកែទំរង់ហិរញ្ញវត្ថុសាធារណៈ
  "ដើម្បីជូនជ្រាប"
- នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន
  "ដើម្បីសហការអនុវត្ត"
- អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ
  "ដើម្បីសហការអនុវត្ត និងផ្សព្វផ្សាយ"
- ឯកសារ- កាលប្បវត្តិ